មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ឯកសារគោលនយោបាយចេញផ្សាយដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ស្តីពីស្ថានភាពបច្ចុប្បន្នរបស់ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១១

## សេចក្តីផ្តើម

ឯកសារគោលនយោបាយនេះត្រូវបានតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ជាអង្គការមិនមែនរដ្ឋាភិបាល (អង្គការ) ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅព្រះរាជាណាចក្រកម្ពុជា (កម្ពុជា)។ គោលបំណងនៃឯកសារគោលនយោបាយនេះ គឺដើម្បីបង្ហាញនូវរូបភាពរួមអំពីស្ថានភាពបច្ចុប្បន្នរបស់ពង្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ច្បាប់) និងសេចក្តីព្រួយបារម្ភសំខាន់ៗរបស់ ម.ស.ម.ក ដោយសំយោគអនុសាសន៍ដែលបានផ្តល់ជូនលើពង្រាងច្បាប់មុនៗ។ សូមបញ្ជាក់ថាអត្ថបទយោងដែលបង្ហាញក្នុងឯកសារគោលនយោបាយនេះ ជាពង្រាងលើកទីបីនៃច្បាប់ដែលចែកចាយជាសាធារណៈដោយក្រសួងមហាផ្ទៃនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១។ ឯកសារគោលនយោបាយនេះ ក៏បានលើកនូវអំណះអំណាងប្រឆាំងនឹងការអនុម័តច្បាប់ក្នុងទម្រង់បច្ចុប្បន្ន ដើម្បីជាផលប្រយោជន៍ដល់អ្នកពាក់ព័ន្ធដទៃទៀត។ ឯកសារគោលនយោបាយនេះមានបំណងសម្រេចបាននូវចំណុចមួយចំនួនដូចខាងក្រោម ៖

- បង្ហាញពីសារតារនៃច្បាប់ និងហេតុផលដែលបានផ្តល់ក្នុងការស្នើអនុម័តច្បាប់
- ផ្តល់នូវព័ត៌មានថ្មីៗថាច្បាប់បានមកដល់ដំណាក់កាលណានៃដំណើរការអនុម័ត
- សង្ខេបពីដំណើរការពិគ្រោះយោបល់របស់សង្គមស៊ីវិលក្នុងពេលបច្ចុប្បន្ន
- បញ្ជាក់សាជាថ្មីពីគោលជំហរប្រឆាំងចម្បងរបស់ ម.ស.ម.ក ចំពោះច្បាប់ក្នុងទម្រង់បច្ចុប្បន្ន
- គូសបញ្ជាក់ពីមូលហេតុដែលច្បាប់នេះនឹងរំលោភលើសិទ្ធិសេរីភាពជាមូលដ្ឋានយ៉ាងធ្ងន់ធ្ងរ
- បង្ហាញពីអំណះអំណាងប្រឆាំងនឹងច្បាប់ផ្អែកលើគំនិតរបស់អាជីវកម្មនៅបស្ចិមប្រទេស
- ពន្យល់ពីហេតុផលដែលច្បាប់អាចប៉ះពាល់ដល់ "ប្រសិទ្ធភាពនៃការអភិវឌ្ឍន៍" ប្រសិនបើច្បាប់នេះត្រូវបានអនុម័ត
- ផ្តល់អនុសាសន៍ដល់អ្នកពាក់ព័ន្ធដទៃពីសកម្មភាពដែលពួកគេអាចធ្វើដើម្បីរារាំងច្បាប់នេះ និង
- ទាញសេចក្តីសន្និដ្ឋានអំពីច្បាប់ និងភាពជោគជ័យអ្វីខ្លះដែលច្បាប់នេះមានបំណងសម្រេចបាន។

## <u>សារតារ</u>

រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ជាច្រើនលើកច្រើនសាមានបំណងចង់គ្រប់គ្រងអង្គការសង្គមស៊ីវិលនៅកម្ពុជា តែមិនទាន់បានជោគជ័យនៅឡើយ។ មានហេតុផលមួយចំនួនត្រូវបានអះអាងក្នុងការដាក់ច្បាប់គ្រប់គ្រងអង្គការដែលកំពុងធ្វើប្រតិបត្តិការនៅកម្ពុជា ក្នុងនោះ រដ្ឋាភិបាលបានលើកឡើងថាការបង្កើតច្បាប់នេះ គឺដើម្បីការពារបទល្មើសរហូតដល់ការបង្ក្រាបភេរវកម្ម ដែលសុទ្ធតែជាអំណះអំណាងគួរឲ្យសង្ស័យ។ រដ្ឋាភិបាលបានលើកយក តម្លាភាពរបស់អង្គការ (សំខាន់បំផុតគឺរឿងថវិកា) ជាមូលហេតុមួយនៃការបង្កើតច្បាប់ ប៉ុន្តែគួរតែបញ្ជាក់ផងដែរថាអង្គការទាំងអស់សុទ្ធតែតម្រូវឲ្យទទួលខុសត្រូវចំពោះម្ចាស់ជំនួយរបស់ខ្លួន ពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ និងសវនកម្មជារៀងរាល់ឆ្នាំ។ ជាទូទៅ អ្នករិះគន់ចំពោះច្បាប់នេះ បានចាត់ទុកហេតុផលទាំងនោះថាជាលេសបិទបាំងចេតនាផ្សេងទៀត ដែលត្រូវបានមើលឃើញថាជាហេតុផលពិតប្រាកដនៃការអនុម័តច្បាប់នេះ មានដូចជា បង្ក្រាបការជំទាស់ បំបិទមាត់អ្នកនយោបាយគណបក្សប្រឆាំង និងបន្តក្តោបក្តាប់អំណាចដោយមិនព្រមលែង។ ទោះបីជាមានការរិះគន់យ៉ាងខ្លាំងពីសំណាក់សង្គមស៊ីវិល និងសហគមន៍អន្តរជាតិ រួមទាំងម្ចាស់ជំនួយផងដែរ ព្រមជាមួយសំណួរពីភាពចាំបាច់នៃការបង្កើតច្បាប់នេះ រដ្ឋាភិបាលក៏នៅតែបន្តដំណើរការនេះដោយមិនអើពើ នេះបង្ហាញនូវការប្តេជ្ញាចិត្តដ៏មុតមាំក្នុងការដាក់សង្គមស៊ីវិល ដែលជាសំឡេងឯករាជ្យចុងក្រោយមួយនៅកម្ពុជា មកនៅក្រោមអំណាចរបស់ខ្លួន។

## <u>ចំណុចដែលមិនអាចបកក្រោយ</u>

ម.ស.ម.ក ជាមួយនឹងតំណាងអង្គការទាំងជាតិ និងអន្តរជាតិ បានចូលរួមកិច្ចប្រជុំជាមួយក្រសួងមហាផ្ទៃកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១។ ម.ស.ម.ក បានសរសេរលិខិតទៅកាន់ក្រសួងមហាផ្ទៃដើម្បីស្នើសុំនូវពង្រាងច្បាប់លើកទីបី និងបានស្នើសុំឲ្យមានការពិគ្រោះយោបល់ដ៏ពិតប្រាកដមួយ។ ប៉ុន្តែ ពង្រាងច្បាប់លើកទីបី ត្រូវបានចែកចាយក្នុងកិច្ចប្រជុំជាមួយក្រសួងមហាផ្ទៃ ហើយដោយមិនចាប់អារម្មណ៍ពីសំណើរបស់តំណាងអង្គការសង្គមស៊ីវិលដែលស្នើសុំរយៈពេល មួយសប្តាហ៍ដើម្បីផ្តល់យោបល់ចុងក្រោយលើពង្រាងច្បាប់ដែលទើបផ្តល់ជូននេះ រដ្ឋាភិបាលបានបញ្ជាក់ថាពង្រាងច្បាប់លើកទីបី បានបញ្ជូនទៅគណៈរដ្ឋមន្ត្រីមុនពេលរៀបចំកិច្ចប្រជុំនេះទៅទៀត មិនតែប៉ុណ្ណោះ ឯកឧត្តម នុត សាអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ហាក់ដូចជាចង់បង្ហាញថាវាហួសពេលសម្រាប់ឲ្យអង្គការសង្គមស៊ីវិលផ្តល់យោបល់ហើយ។ ក្រោយពេលចប់ការប្រជុំ នៅពេលដែលមានសំណួរថា តើលោកនៅតែទទួលយកមតិយោបល់បន្ថែមពីសង្គមស៊ីវិលដែរឬទេ លោកបាននិយាយថា "*អង្គការសង្គមស៊ីវិលមិនគួរព្រួយបារម្ភពីច្បាប់នេះទៀតទេ*"។ លោកនិយាយទៅកាន់ វិទ្យុសំឡេងសហរដ្ឋអាមេរិកថា អង្គការ ប្រហែលជាត្រូវដាក់ស្នើយោបល់ដោយផ្ទាល់ទៅកាន់គណៈរដ្ឋមន្ត្រី ប្រសិនបើពួកគេចង់ឲ្យមានការផ្លាស់ប្តូរបន្ថែមទៀត ប៉ុន្តែគណៈរដ្ឋមន្ត្រីបាន

បញ្ជាក់ថាគ្មានគម្រោងនឹងទទួលយកមតិយោបល់បន្ថែមទេ អង្គការគួរតែទាក់ទងទៅក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជំនួសវិញ។[1]

បើទោះបីជាការអះអាងទាំងនេះដូចជាមានលក្ខណៈផ្ទុយគ្នាក៏ដោយ សាររបស់រដ្ឋាភិបាលហាក់ដូចជាចង់បង្ហាញថាច្បាប់នេះបានឆ្លងផុតដំណាក់កាលដែលសង្គមស៊ីវិលនៅម្តុជាត្រូវផ្តល់យោបល់ ជះឥទ្ធិពល ឬរារាំងការអនុម័តច្បាប់នេះហើយ។ នៅមិនទាន់មានការបញ្ជាក់ច្បាស់នៅឡើយទេថា តើគណៈរដ្ឋមន្ត្រីនឹងជួបប្រជុំដើម្បីអនុម័តច្បាប់ជាលើកចុងក្រោយក្នុងកម្រិតរដ្ឋាភិបាលនៅពេលណានោះទេ ប៉ុន្តែមានការរំពឹងទុកថាប្រហែលជាអាចក្នុងរយៈពេលពីរបីថ្ងៃខាងមុខ។ ពេលដែលច្បាប់ឆ្លងកាត់ការយល់ព្រមពីគណៈរដ្ឋមន្ត្រី ច្បាប់នឹងត្រូវបញ្ជូនបន្តទៅរដ្ឋសភា ហើយបន្ទាប់មកទៅព្រឹទ្ធសភា។ បទពិសោធន៍ច្បាប់ដទៃ បង្ហាញថាដំណើរការអនុម័តនឹងមិនចំណាយពេលយូរនោះទេ មានន័យថាច្បាប់នេះអាចនឹងត្រូវអនុម័តនៅដើមខែក្រោយ ហើយយោងតាមច្បាប់តម្រូវឲ្យមានរយៈពេល ៣៦៥ថ្ងៃនៃថ្ងៃធ្វើការសម្រាប់អង្គការ ឬសមាគមនីមួយៗរៀបចំ និងដាក់ស្នើឯកសារចាំបាច់មួយចំនួនដើម្បីចុះបញ្ជី និងចុះបញ្ជីសាជាថ្មី (មាត្រា៥៥)។ ការណ៍នេះហាក់ដូចជាចង់បង្ហាញថាចំណុចមិនអាចបកក្រោយកាន់តែខិតចូលមកជិត ហើយនៅសល់ឱកាសតិចតួចប៉ុណ្ណោះក្នុងការជះឥទ្ធិពលលើការអនុម័ត និងខ្លឹមសារនៃច្បាប់។ ប្រសិនបើដូច្នេះ នេះជាពេលដែលអ្នកពាក់ព័ន្ធផ្សេងៗត្រូវចាប់ផ្តើមធ្វើសកម្មភាពក្នុងកម្រិតខ្ពស់មួយតាមដែលអាចធ្វើទៅបានដើម្បីធានាថាច្បាប់នេះនឹងមិនត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ននេះ។

## កង្វះការពិគ្រោះយោបល់ដ៏ពិតប្រាកដ

ក្នុងរយៈពេលមួយឆ្នាំជាង អង្គការ និងតួអង្គសង្គមស៊ីវិលដទៃទៀតនៅកម្ពុជា បានអំពាវនាវឲ្យរាជរដ្ឋាភិបាលធានាថាដំណើរការពិគ្រោះយោបល់សម្រាប់ច្បាប់នេះ ជាដំណើរការបើកចំហ និងទូលំទូលាយដែលរួមបញ្ចូលរាល់ភាគីដែលរងផលប៉ះពាល់នៃច្បាប់នេះ។ ប៉ុន្តែ ក្នុងដំណើរការនៃការបង្កើតច្បាប់ រដ្ឋាភិបាលត្រូវបានរងការរិះគន់ពីសំណាក់ អង្គការ រួមទាំងម្ចាស់ជំនួយដោយសារខកខានមិនបានបង្កើតការពិគ្រោះយោបល់បែបបើកចំហ ឬពិតប្រាកដ ជាមួយអង្គការ សមាគម និងតួអង្គសង្គមស៊ីវិលដទៃទៀត។ ការពង្រាងច្បាប់ ត្រូវបានធ្វើឡើងដោយអាថ៌កំបាំងបំផុត ចំណែកការពិគ្រោះយោបល់វិញក៏មានតិចតួចបំផុត ហើយកិច្ចពិភាក្សាមួយជាមួយអង្គការមួយចំនួនមានត្រឹមតែមួយថ្ងៃគត់ គឺនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១។ មានតំណាងអង្គការមួយចំនួនតូចត្រូវបានអញ្ជើញដោយក្រសួងមហាផ្ទៃដើម្បីចូលរួមការប្រជុំនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ ដើម្បីពិភាក្សាពង្រាងលើកទីពីរ ជាមួយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ អង្គការដែលត្រូវបានជ្រើសរើសឲ្យចូលរួមការប្រជុំនេះបានចាត់ទុកថាការប្រជុំនេះ គឺគ្រាន់

[1] ថូម៉ាស មីល័រ "ពង្រាងច្បាប់អង្គការប្រមូលផ្តុំនូវភាពជឿនលឿន" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១

តែជាការខិតខំប្រឹងប្រែងដ៏ស្តួចស្តើងដើម្បីសុំការយល់ព្រមពីសង្គមស៊ីវិល ហើយសូមបញ្ជាក់ផងដែរថាចរិតលក្ខណៈ និងរយៈពេលនៃការប្រជុំមិនបានបំពេញតាមលក្ខខណ្ឌការពិគ្រោះយោបល់ដ៏ពិតប្រាកដ ដែលការបង្កើតច្បាប់សំខាន់ៗបែបនោះគួរតែមាន និងតម្រូវឲ្យមានជាចាំបាច់។

ពង្រាងច្បាប់លើកទីពីរត្រូវបានចេញផ្សាយជាសាធារណៈ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ត្រឹមតែបួនថ្ងៃមុនកិច្ចប្រជុំជាមួយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ក្នុងរយៈពេល ៤ថ្ងៃនោះ មានរយៈពេល២ថ្ងៃជាថ្ងៃឈប់សម្រាក ដូច្នេះមិនមែនជាពេលវេលាគ្រប់គ្រាន់សម្រាប់ឲ្យភាគីពាក់ព័ន្ធទាំងអស់ធ្វើការវិភាគយ៉ាងម៉ត់ចត់ចំពោះការផ្លាស់ប្តូរច្បាប់ដែលមានភាពចម្រូងចម្រាស់ និងមានឥទ្ធិពលបែបនោះទេ។ រយៈពេលដ៏សមរម្យគួរតែត្រូវបានកំណត់ដើម្បីអនុញ្ញាតឲ្យសាធារណជនមានឱកាសគ្រប់គ្រាន់ដើម្បីវិភាគពង្រាងលើកទីពីរ និងដើម្បីរៀបចំឲ្យមានកិច្ចប្រជុំដ៏សមរម្យមួយជាមួយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ម្យ៉ាងវិញទៀត ដោយសារតែពង្រាងនេះត្រូវបានចេញផ្សាយតែជាភាសាខ្មែរ អង្គការអន្តរជាតិដែលប្រើប្រាស់តែភាសាអង់គ្លេស និងបានទទួលរងឥទ្ធិពលពីច្បាប់នេះដែរនោះ ត្រូវបានបដិសេធនូវឱកាសស្មើភាពក្នុងការវិភាគពង្រាងច្បាប់លើកទីពីរនេះ។

**មកទល់បច្ចុប្បន្ន ដោយសារតែគ្មានការ "ពិគ្រោះយោបល់ដ៏ពិតប្រាកដ" នៃច្បាប់នេះ និងផ្អែកលើការពិតដែលច្បាប់នេះត្រូវបានបញ្ជូនទៅគណៈរដ្ឋមន្ត្រីហើយ ចំណុចនេះ ហាក់ដូចជាបង្ហាញថាសង្គមស៊ីវិលនៅកម្ពុជា ត្រូវបានបដិសេធឱកាសក្នុងការពិគ្រោះយោបល់ដ៏ពិតប្រាកដ ដែលពួកគាត់រំពឹងថាអាចមាន និងបានស្នើសុំមុនពេលច្បាប់ត្រូវបានអនុម័ត។ ម្យ៉ាងវិញទៀត ក្រសួងមហាផ្ទៃបានផ្តល់យោបល់ថាពង្រាងលើកទីបី ប្រហែលជាមិនមែនជាពង្រាងចុងក្រោយនោះទេដោយសារតែអាចនឹងមានការផ្លាស់ប្តូរដែលធ្វើឡើងដោយគណៈរដ្ឋមន្ត្រី ដូច្នេះសង្គមស៊ីវិលពិតជាមិនអាចដឹងបានទេថាពង្រាងចុងក្រោយនៃច្បាប់នេះនឹងមានមាត្រាចែងពីចំណុចអ្វីខ្លះ។**

## គោលជំហរបដិសេធរបស់ ម.ស.ម.ក ចំពោះពង្រាងច្បាប់

### សមាគម

ពង្រាងលើកទីបីនៃច្បាប់មិនបានផ្លាស់ប្តូរសេចក្តីព្រួយបារម្ភចម្បងរបស់ ម.ស.ម.ក នោះទេ ពោលគឺច្បាប់នឹងនៅបន្តជះឥទ្ធិពលខ្លាំងក្លាបំផុតមកលើ (១) អង្គការមហាជនដែលរួមមានក្រុមមានប្រជាប្រិយភាពមិនផ្លូវការ និងបណ្តាញមូលដ្ឋាន និង (២) អង្គការតូចៗ និងថ្នាក់ខេត្ត បង្ហាញថាគោលបំណងសំខាន់របស់រាជរដ្ឋាភិបាលក្នុងការអនុម័តច្បាប់ គឺមិនមែនមានបំណងគ្រប់គ្រងអង្គការអន្តរជាតិ និងជាតិដែលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញនោះទេ ប៉ុន្តែដើម្បីបង្ក្រាបសកម្មភាពដែលមានប្រជាប្រិយភាព និងនយោបាយនៅថ្នាក់មូលដ្ឋាន។ ក្រុមទាំងនោះ ជាឆ្អឹងខ្នងរបស់សង្គមស៊ីវិល ហើយក្រុមទាំងនោះនឹងស្ថិតក្នុងស្ថានភាពដ៏ពិបាកក្នុងការប្រឈមជាមួយនឹងតម្រូវការនីតិវិធីដ៏ស្មុគស្មាញ។ ក្រុមទាំងនោះគួរតែត្រូវបានការពារដោយច្បាប់ តែមិនគួរប្រឈមនឹង

"មរណភាពដោយសារការិយាធិបតេយ្យ" ដែលអាចជាកេរ្តិ៍ដំណែលនៃច្បាប់នេះប្រសិនបើច្បាប់ត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ន។

តាមទម្រង់នេះ ច្បាប់នៅតែដាក់បន្ទុកមកលើ "សមាគម" ដែលជា "ក្រុមរួបរវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលបានព្រមព្រៀងគ្នាបង្កើតឡើង ដើម្បីគិតគូពីផលប្រយោជន៍សមាជិក ឬ/និងផលប្រយោជន៍សាធារណៈ ដោយមិនធ្វើសកម្មភាពណាមួយទាញយកប្រាក់ចំណេញមកចែកដល់សមាជិកនោះទេ" (មាត្រា ៤) ជានិយមន័យដ៏ទូលាយ និងមានវិសាលភាពធំក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជី។ ម្យ៉ាងវិញទៀត ការលើកលែងចំពោះសម្រាប់សមាគមក្នុងច្បាប់នេះ ដូចមានចែងក្នុងពង្រាងលើកទីពីរ ដែលចែងថា "អង្គការមហាជនដែលបង្កើតតាមមូលដ្ឋានមិនស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ ហើយធ្វើសកម្មភាពស្របតាមច្បាប់នានាជាធរមានដើម្បីជួយគ្នាទៅវិញទៅមក" ត្រូវបានដកចេញ។ មិនមានភាពច្បាស់លាស់ ថា មាត្រា ៨ ដែលចែងពីលក្ខខណ្ឌនៃចំនួនសមាជិកស្ថាបនិកអប្បបរមារបស់សមាគម នឹងប៉ះពាល់ដល់និយមន័យពាក្យ "សមាគម" និងការដាក់ពាក្យស្នើសុំចុះបញ្ជី ដែលការណ៍នេះគួរតែត្រូវផ្តល់និយមន័យឲ្យច្បាស់ក្នុងមាត្រា ៤។ តាមទម្រង់នេះ ក្នុងពង្រាងច្បាប់លើកទីពីរ ចំណុចចាប់ផ្តើមនៃការចុះបញ្ជីរបស់សមាគមគឺត្រូវមានសមាជិកស្ថាបនិកជាប្រជាពលរដ្ឋកម្ពុជា ចំនួន ១១នាក់។ ដូច្នេះ គ្មានភាពច្បាស់លាស់ ថាតើសមាជិកស្ថាបនិកជាប្រជាពលរដ្ឋកម្ពុជាចំនួន ១០នាក់ មានលទ្ធភាពអាចបង្កើតសមាគមបានដែរឬទេ តែប្រសិនបើតាមនិយមន័យដ៏ទូលាយក្នុងមាត្រា ៤ គឺអាចបកស្រាយថា "បាន"។ ប៉ុន្តែ ជាការចាំបាច់ដែលក្រុមទាំងនោះដឹង ថាតើពួកគេកំពុងតែអនុវត្តសកម្មភាពដោយខុសច្បាប់ដែរឬទេ ប្រសិនបើពួកគេនៅមិនទាន់បានចុះបញ្ជី បើយោងតាមមាត្រា ៨ ពួកគេមិនអាចចុះបញ្ជីបានទេ ប្រសិនបើគ្មានចំនួនសមាជិកស្ថាបនិកគ្រប់គ្រាន់។

ការអនុវត្តន៍បែបនេះអាចនឹងបង្ក្រាបចំពោះអង្គការមហាជន (ជាទូទៅចាត់ទុកថាជា "សមាគម") ដែលជាញឹកញាប់ជួបប្រជុំ និងបង្កើតឡើងដោយផ្អែកលើមូលដ្ឋានពិសេស ដោយបុគ្គលមួយក្រុមតូចដែលពាក់ព័ន្ធដើម្បី បញ្ចេញ លើកកម្ពស់ បន្ត និងការពារផលប្រយោជន៍រួម ឬដើម្បីឆ្លើយតបចំពោះបញ្ហាជាក់លាក់ ហើយនេះនឹងអាចរំលោភសិទ្ធិសេរីភាពមូលដ្ឋានក្នុងការប្រមូលផ្តុំ និងបញ្ចេញមតិ ក៏ដូចជាសិទ្ធិ "*ចូលរួមយ៉ាងសកម្មនៅក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ*" ដូចបានចែងក្នុងមាត្រា ៣៥ ក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ)។ ម.ស.ម.ក រក្សានូវគោលជំហមួយថាច្បាប់គួរតែត្រូវកែលម្អដើម្បីមិនឲ្យច្បាប់នេះដាក់បន្ទុកទៅលើ "សមាគម" ប៉ុន្តែសម្រាប់តែអង្គការទាំងជាតិ និងអន្តរជាតិអនុវត្តប៉ុណ្ណោះ។

## សិទ្ធិប្តឹងជំទាស់

ម.ស.ម.ក ស្វាគមន៍នូវការពិតដែលក្រសួងមហាផ្ទៃ បានស្តាប់អនុសាសន៍របស់អង្គការ និងម្ចាស់ជំនួយ និងបានដាក់បញ្ចូលសិទ្ធិប្តឹងជំទាស់នៅក្នុងពង្រាងច្បាប់លើកទីបី និងចំណុចមួយ

ទៀតដែលអនុញ្ញាតឲ្យប្តឹងតវ៉ាទៅតុលាការ មិនមែនត្រលប់មកក្រសួងដោយផ្ទាល់ (មាត្រា១៧)។ ប៉ុន្តែ ជាការចម្លែកដែលសិទ្ធិប្តឹងជំទាស់ការបដិសេធមិនទទួលពាក្យស្នើសុំចុះបញ្ជី ត្រូវបានផ្តល់ទៅអង្គការ និងសមាគមជាតិ តែចំពោះអង្គការអន្តរជាតិគឺមិនបានទទួលសិទ្ធិនេះទេ។ ផ្ទុយមកវិញ អង្គការអន្តរជាតិដែលដាក់ពាក្យស្នើសុំចុះបញ្ជី (ប៉ុន្តែមិនមែនអង្គការជាតិ) នឹងទទួលបានលិខិតជាលាយលក្ខណ៍អក្សរដើម្បីពន្យល់ពីមូលហេតុដែលពាក្យស្នើសុំចុះបញ្ជីត្រូវបានបដិសេធ។ម្យ៉ាងវិញទៀត គ្មានរយៈពេលកំណត់ពាក់ព័ន្ធនឹងសិទ្ធិប្តឹងជំទាស់ មានន័យថាដំណើរការប្តឹងជំទាស់អាចនឹងបន្តដោយគ្មានកាលកំណត់ ដែលនេះជាពេលវេលាគួរឲ្យពិចារណា ដោយហេតុថាគ្មានបញ្ញត្តិណាអនុញ្ញាតឲ្យអង្គការ ឬសមាគមអាចបន្តធ្វើសកម្មភាពខណៈពេលដែលដំណើរការបណ្តឹងជំទាស់កំពុងប្រព្រឹត្តទៅឡើយ។ ការមិនដាក់បញ្ចូលនូវបញ្ញត្តិនេះ គឺជាអ្វីដែលយើងត្រូវត្រួតពិនិត្យឲ្យបានច្បាស់ដោយហេតុថារយៈពេលសម្រាប់ការអនុញ្ញាឲ្យចុះបញ្ជី (រយៈពេល៤៥ថ្ងៃនៃថ្ងៃធ្វើការ) អំឡុងពេលដែលអង្គការ ឬសមាគមដែលដាក់ពាក្យស្នើសុំចុះបញ្ជីមិនអាចធ្វើសកម្មភាពបាននោះទេ។ បើទោះបីជាមានភាពស្រពេចស្រពិល និងមើលរំលងបែបនេះក៏ដោយ ការណ៍ដែលដាក់បញ្ចូលនូវសិទ្ធិប្តឹងជំទាស់ ជាចំណុចគួរឲ្យស្វាគមន៍ ទោះបីជាតុលាការនៅមិនទាន់ឯករាជ្យពីនីតិប្រតិបត្តិក៏ដោយ។ សេចក្តីព្រួយបារម្ភស្តីពីប្រព័ន្ធតុលាការ គឺហួសពីវិសាលភាពនៃឯកសារគោលនយោបាយនេះ។

## ការចុះបញ្ជី

ខណៈពេលដែលពង្រាងច្បាប់លើកទីបី បានបង្ហាញឲ្យឃើញពីការវិវឌ្ឍន៍ខ្លះនៅក្នុងដំណើរការចុះបញ្ជី (សូមអានខាងលើស្តីពីសិទ្ធិប្តឹងជំទាស់ និងអំឡុងពេលត្រួតពិនិត្យការចុះបញ្ជីសាជាថ្មីគឺ ៤៥ថ្ងៃនៃថ្ងៃធ្វើការ ដូចពង្រាងច្បាប់លើកទីមួយ) តម្រូវការចុះបញ្ជីគឺនៅតែស្មុគស្មាញ និងធ្ងន់ធ្ងរហួសហេតុ។ តុល្យភាពនៃការបំពេញតាមភាពស្របច្បាប់ និងការព្រួយបារម្ភដ៏សមហេតុផលរបស់រដ្ឋាភិបាល និងផ្តល់សេរីភាពឲ្យអង្គការ និងសមាគមក្នុងការអនុវត្តសកម្មភាពជាវិជ្ជមាន និងមានប្រយោជន៍ គឺជាការចាំបាច់ត្រូវតែមាន។ ម្យ៉ាងវិញទៀត ដំណើរការចុះបញ្ជីគឺខ្វះខាតសេចក្តីណែនាំ និងទម្រង់ជាបទដ្ឋាន។ ការខ្វះខាតនៃសេចក្តីណែនាំ និងតម្រូវការចុះបញ្ជីដ៏ស្មុគស្មាញមានន័យថា អង្គការមហាជន និង/ឬ អង្គការថ្នាក់ខេត្តតូចៗនឹងទទួលរងឥទ្ធិពលខ្លាំងបំផុត ដោយសារតែសមត្ថ-ភាព និងធនធានមានកំណត់។

មួយវិញទៀត ច្បាប់នៅតែមិនអាចផ្តល់នូវលក្ខខណ្ឌវាយតម្លៃជាលម្អិតដែល អង្គការ ឬសមាគមដាក់ពាក្យស្នើសុំចុះបញ្ជីនឹងត្រូវបានវាយតម្លៃ មានន័យថា គោលការណ៍តម្លាភាព និងគណនេយ្យភាពនៅតែមិនទាន់ត្រូវបានគោរពនៅឡើយ។ លក្ខខណ្ឌដែលក្រសួងមហាផ្ទៃអាចបដិ-សេធការដាក់ពាក្យស្នើសុំចុះបញ្ជី មិនត្រូវបានកំណត់ក្នុងច្បាប់ ដែលជាឆន្ទានុសិទ្ធិទាំងស្រុងរបស់ក្រសួងមហាផ្ទៃ (មាត្រា ១៧ និង៣២)។ ដំណើរការចុះបញ្ជីគួរតែត្រូវបង្កើតឡើងដោយមិនលម្អៀង

និងគ្មានការជំរុញពីកត្តានយោបាយ។ ប្រសិនបើគ្មានការវាយតម្លៃលើលក្ខខណ្ឌនៅក្នុងច្បាប់ស្តីពីការបដិសេធនៃសំណើចុះបញ្ជី មានការព្រួយបារម្ភថារដ្ឋាភិបាលនឹងមានឱកាសកេញផលចំណេញដោយអាចលើកយក "កំហុសផ្នែករដ្ឋបាល" ប្រើប្រាស់ជាវិធីបដិសេធការដាក់ពាក្យស្នើសុំចុះបញ្ជី ឬចុះបញ្ជីសាជាថ្មីរបស់អង្គការ "ដែលមិនគួរឲ្យពេញចិត្ត" ជាពិសេស អង្គការដែលរិះគន់រដ្ឋាភិបាល និងសកម្មភាពរបស់រដ្ឋាភិបាល អាចនឹងត្រូវបានបដិសេធពាក្យស្នើសុំចុះបញ្ជីដោយគ្មានការពន្យល់ ឬក៏ផ្អែកលើមូលដ្ឋានកំហុសផ្នែករដ្ឋបាល។ គួរតែមានមូលហេតុច្បាស់លាស់ និងអាចព្យាករណ៍បានក្នុងការបដិសេធពាក្យស្នើសុំចុះបញ្ជី ដើម្បីកាត់បន្ថយអំណាចឆន្ទានុសិទ្ធិរបស់រដ្ឋាភិបាល ក្រសួងមហាផ្ទៃ ឬករណីរបស់អង្គការអន្តរជាតិ គឺក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរ-ជាតិ។ម្យ៉ាងវិញទៀត គ្មានបទបញ្ញត្តិសម្រាប់ការចុះបញ្ជីដោយស្វ័យប្រវត្តិក្នុងករណីដែលក្រសួងមហាផ្ទៃមិនអាចត្រួតពិនិត្យមើលពាក្យស្នើសុំចុះបញ្ជីក្នុងរយៈពេល ៥៥ថ្ងៃនៃថ្ងៃធ្វើការ (មាត្រា១៧ និង៣២)។ ដំណើរការចុះបញ្ជី និងដំណើរការពាក់ព័ន្ធទាំងអស់គួរតែ និងត្រូវបានឃើញថា មានតម្លាភាព និងគ្មានអំពើពុករលួយ និងឥទ្ធិពលពីនយោបាយ។

## ការតាមដាន និងគ្រប់គ្រង

ច្បាប់តម្រូវថារបាយការណ៍ប្រចាំឆ្នាំត្រូវតែបញ្ជូនទៅកាន់ស្ថាប័ននីតិប្រតិបត្តិដែលពាក់ព័ន្ធ ដែលតម្រូវការនេះជាការដាក់បន្ទុកដល់អង្គការមហាជន អង្គការតូចៗ និង/ឬថ្នាក់ជាតិដែលមានរចនាសម្ព័ន្ធគ្រប់គ្រងបែបធូររលុង និង/ឬមានជំនួយផ្នែករដ្ឋបាលបន្តិចបន្តួច ជាលទ្ធផលក្រុមទាំងនេះអាចនឹងត្រូវបានគេគម្រាម និងបំបាក់ទឹកចិត្តដោយសារតែតម្រូវការផ្នែករបាយការណ៍ដែលមិនចាំបាច់ និងគ្មានលក្ខណៈពិតប្រាកដ។ និយមន័យដ៏ទូលាយនៃពាក្យថា "សមាគម" ក្រុមដទៃផ្សេងទៀតក៏អាចទទួលរងឥទ្ធិពល និងត្រូវបានបដិសេធដោយតម្រូវការផ្នែករបាយការណ៍ដ៏ធ្ងន់ធ្ងរនេះផងដែរ។ បញ្ញត្តិក្នុងការតាមដាន និងគ្រប់គ្រងរបស់អង្គការ និងសមាគមគួរតែមិនហួសហេតុពេក ឬមានការរំខាន ហើយប្រព័ន្ធនៃការធ្វើរបាយការណ៍ប្រចាំឆ្នាំអាចជាការរំខានយ៉ាងខ្លាំង និងអាចមានលទ្ធផលជាការបំពាន និងយាយីមកលើអង្គការ និងសមាគម។ ម្យ៉ាងវិញទៀត ហេតុផលនៅពីក្រោយប្រព័ន្ធតាមដាន និងគ្រប់គ្រងគួរតែត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់។

## បទល្មើស និងទោសប្បញ្ញត្តិ

ក្នុងពង្រាងច្បាប់លើកទីបី បទល្មើស និងទោសប្បញ្ញត្តិ ចំពោះការរំលោភច្បាប់គឺនៅតែ (១) មានភាពធ្ងន់ធ្ងរបែបមិនសមាមាត្រ និងមិនសមហេតុផល (២) ពង្រាងមិនច្បាស់លាស់ ដូច្នេះគឺបើកចំហឲ្យមានការបកស្រាយខុស និងការរំលោភបំពាន និង (៣) មានការរើសអើង។ ឧទាហរណ៍ អង្គការអន្តរជាតិដែលខកខានមិនបានបំពេញតាមតម្រូវការផ្នែករបាយការណ៍អាចប្រឈមមុខនឹងការព្យួរសកម្មភាព និងបញ្ចប់អនុស្សរណៈ (មាត្រា៤៦ និង៥៣) ប៉ុន្តែ នៅក្នុងមាត្រា៤៩ របស់ច្បាប់

ដែលចែងថាការរំលាយចោលដោយគ្មានការយល់ព្រម ដោយតុលាការក៏ចាត់ទុកជាទណ្ឌកម្មដែលអាចអនុវត្តបានចំពោះអង្គការ យោងតាមពង្រាងមិនច្បាស់លាស់នៃបញ្ញត្តិផ្សេងៗនៃច្បាប់ ទោះជាមិនច្បាស់ថានៅក្រោមកាលៈទេសៈណាក៏ដោយ។ មួយវិញទៀត មាត្រា៥៤ ចែងថា "ក្នុងករណីមិនរាលចាល ឬករណីរំលោភបំពានធ្ងន់ធ្ងរលើរដ្ឋធម្មនុញ្ញ និងច្បាប់ដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា អង្គការ ឬសមាគម នឹងត្រូវបានដាក់ទារុណកម្មយោងតាមច្បាប់ជាធរមាន។" ពង្រាងមាត្រានេះគឺគ្មានភាពច្បាស់លាស់ដែលអង្គការ ឬសមាគមមិនច្បាស់ថាបទល្មើសមជ្ឈិមបែបណាដែលគ្របដណ្តប់លើ និងទោសទណ្ឌបែបណាដែលពួកគេត្រូវប្រឈម។ ចុងក្រោយ ពង្រាងច្បាប់លើកទីបី មិនបានបង្ហាញពីលក្ខខណ្ឌក្នុងកាលៈទេសៈដែល អង្គការ ឬសមាគម អាចត្រូវបានផ្អាក ឬត្រូវរំលាយ ទុកឲ្យរូបភាព និងការអនុវត្តរបស់ច្បាប់ទាំងមូលមានភាពមិនច្បាស់លាស់ និងមិនអាចព្យាករណ៍បាន។

ពិតជាមានសារៈសំខាន់ណាស់ដែលលក្ខខណ្ឌបទល្មើស និងទោសប្បញ្ញត្តិត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់ មានគោលការណ៍ អាចព្យាករណ៍បាន និងស្របទៅនឹងច្បាប់អន្តរជាតិ។ បទល្មើស និងទោសប្បញ្ញត្តិ គួរតែត្រូវបានគ្រប់គ្រងដោយតុលាការ ដោយសារតែបទល្មើស និងទោសប្បញ្ញត្តិរបស់រដ្ឋាភិបាល ក្រសួង ឬ អង្គនីតិប្រតិបត្តិអាចមានលក្ខណៈតាមអំពើចិត្ត និងធ្ងន់ធ្ងរដោយមិនសមហេតុផល។ ចុងក្រោយ ការចែកដាច់រវាងអង្គការជាតិ និងអន្តរជាតិបង្ហាញពីភាពមិនសមាមាត្រ និងរើសអើង (សូមចងចាំការព្រមានខាងលើ) និងដូច្នេះការចែកដាច់បែបនេះគួរត្រូវតែលុបបំបាត់។

## សេរីភាពជាមូលដ្ឋាន

មាត្រា៤១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៩ និង២១ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាទទួលស្គាល់ និងចុះសច្ចាប័នក្នុងឆ្នាំ ១៩៩២ និងបានបញ្ចូលទៅក្នុងច្បាប់ជាតិរបស់កម្ពុជាយោងតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញបានការពារ និងលើកកម្ពស់សិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបប្រជុំ។ ម្យ៉ាងវិញទៀត មាត្រា៣៥ នៃ រដ្ឋធម្មនុញ្ញ "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ"។

ប៉ុន្តែតាមបទពិសោធន៍ អាជ្ញាធរបានព្រងើយកន្តើយចំពោះលិខិតុបករណ៍ទាំងនេះដោយទទូចដើម្បីហាមឃាត់បុគ្គល ឬអង្គភាពដែលរិះគន់រដ្ឋាភិបាល និងគណបក្សកាន់អំណាចមិនឲ្យផ្សព្វផ្សាយឲ្យទូលំទូលាយទៅសហគមន៍ផ្សេងៗស្តីពីការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តិដោយបុគ្គល និងក្រុមហ៊ុនដែលមានទ្រព្យសម្បត្តិ និងមានខ្សែបណ្តាញ។ សេរីភាពបញ្ចេញមតិ ត្រូវបានចាត់ទុកជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យក្នុងលំហអន្តរជាតិ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា ការប្រើ-

ប្រាស់សេរីភាពដើម្បីបញ្ចេញសំឡេង ផ្តល់មតិ ឬគំនិតប្រឆាំងនឹងរដ្ឋាភិបាលត្រូវបានគេមើលឃើញក្នុងភាពសង្ស័យ។

**ប្រសិនបើច្បាប់ត្រូវបានអនុម័ត ហើយមានអង្គការ ឬសមាគមមួយចំនួនត្រូវបានបដិសេធមិនឲ្យចុះបញ្ជី មិនថាដោយសារតែមូលហេតុដែលពួកគេមើលទៅហាក់ដូចជា "មិនជាទីពេញចិត្ត" របស់រដ្ឋាភិបាល ឬដោយសារតែពួកគេខ្វះខាតធនធានដើម្បីអនុវត្តតាមតម្រូវការចុះបញ្ជីដ៏ស្មុគស្មាញនោះទេ ច្បាប់នេះនឹងរំលោភដល់សិទ្ធិសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំ ដែលបានចែងទាំងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។**

<u>ច្បាប់ ៖ ឧបសគ្គដល់អាជីវកម្មបស្ចិមប្រទេសនៅកម្ពុជា</u>

ខណៈពេលដែលមិនទាន់បង្ហាញពីផលប៉ះពាល់ជាក់ស្តែងភ្លាមៗ នៃច្បាប់គ្រប់គ្រងអង្គការ និងសមាគមដែលអាចមានមកលើអាជីវកម្ម តែប្រសិនបើច្បាប់នេះត្រូវបានអនុម័ត អាជីវកម្មបស្ចិមប្រទេសដែលធ្វើប្រតិបត្តិការនៅកម្ពុជានឹងទទួលរងផលប៉ះពាល់ជាខ្លាំង។ មូលហេតុគឺ ប្រសិនបើអង្គការតស៊ូមតិត្រូវបានបដិសេធមិនឲ្យចុះបញ្ជីសាជាថ្មីដោយសារតែច្បាប់ ដូច្នេះនឹងគ្មានការតាមដាន នឹងគ្មានអ្នកលើកឡើងពីអំពើពុករលួយក្នុងក្រុមហ៊ុន ឬស្ថាប័នជាតិ។ ផ្ទុយមកវិញ ការខ្វះខាតបែបនេះនឹងនាំឲ្យមានអំពើពុករលួយកាន់តែច្រើន។

កម្ពុជាកំពុងតែព្យាយាមទាក់ទាញវិនិយោគិន និងលំហូមូលធនឲ្យបានកាន់តែច្រើន។ ច្បាប់ស្តីពីអំពើពុករលួយ ទាំងក្នុងស្រុក និងអន្តរជាតិបានដាក់ចេញនូវវិធានថ្មីៗមកលើក្រុមហ៊ុនបរទេសដែលកំពុងធ្វើប្រតិបត្តិការ តែអ្នកជំនាញការបាននិយាយថាការផ្លាស់ប្តូរថ្មីៗក្នុងច្បាប់ អាចផ្លាស់ប្តូរពីរបៀបសម្លឹងមកលើហានិភ័យក្នុងការធ្វើប្រតិបត្តិការនៅកម្ពុជារបស់អាជីវកម្មបស្ចិមប្រទេស។ ជាលទ្ធផលនៃច្បាប់របស់សហរដ្ឋអាមេរិក គឺច្បាប់ស្តីពីសកម្មភាពពុករលួយនៅបរទេស និងច្បាប់ប្រឆាំងអំពើពុករលួយដែលកម្ពុជាទើបនឹងបានអនុម័តក្នុងពេលថ្មីៗ ក្រុមហ៊ុនអាមេរិកជាច្រើនបានដឹងថាពួកគេមិនអាចធ្វើអាជីវកម្មនៅកម្ពុជាបានតទៅទៀតទេ ហើយបញ្ញត្តិប្រឆាំងនឹងការសូកប៉ាន់របស់ច្បាប់ស្តីពីសកម្មភាពពុករលួយបរទេស បានកំណត់ថាសកម្មភាពដែលប្រជាពលរដ្ឋអាមេរិកចំណាយប្រាក់ឲ្យទៅមន្ត្រីបរទេសក្នុងគោលបំណងបើក ឬបន្តអាជីវកម្ម ជំនួស ឬជាមួយនរណាម្នាក់ ឬធ្វើអាជីវកម្មផ្ទាល់ជាមួយនរណាម្នាក់ជាសកម្មភាពខុសច្បាប់ ខណៈពេលដែលច្បាប់ប្រឆាំងអំពើពុករលួយ នឹងដាក់ទោសឲ្យជាប់ពន្ធនាគារពី ៥ទៅ១០ឆ្នាំ ចំពោះការចំណាយថ្លៃសម្របសម្រួលដល់មន្ត្រីរដ្ឋាភិបាល។ ច្បាប់ប្រឆាំងអំពើពុករលួយ ក៏បានដាក់បន្ទុកឲ្យក្រុមហ៊ុនបរទេសធ្វើប្រតិបត្តិការនៅកម្ពុជាទទួលខុសត្រូវចំពោះច្បាប់ស្តីពីអំពើសូកប៉ាន់នៅប្រទេសរបស់គេផងដែរ

ស្របពេលដែលច្បាប់របស់សហរដ្ឋអាមេរិកចែងថា ថ្លៃសម្របសម្រួលនៅបរទេសនឹងស្របច្បាប់ ដរាបណាប្រទេសនោះមិនចាត់ទុកចំណាយនេះជាចំណាយខុសច្បាប់។ មានរបាយការណ៍ថាក្រុមហ៊ុនដឹកជញ្ជូន ហ្វិតអេក (**FedEx**) បានបញ្ចប់ប្រតិបត្តិការរបស់ខ្លួននៅកម្ពុជា ដោយសារតែការ

សូកប៉ាន់ដែលក្រុមហ៊ុននេះត្រូវចំណាយទៅលើមន្ត្រីសាធារណៈដើម្បីអាចធ្វើប្រតិបត្តិការអាជីវកម្មបាន។ ចំណាយទាំងនោះ ហ្វិតអេក និយាយថា "ជាទូទៅគឺតម្រូវដោយ មន្ត្រីគយ និងកាំកុងត្រូលដើម្បីទូទាត់ថ្លៃរត់ការសម្រាប់ការដឹកជញ្ជូនធំៗ"។[2] ច្បាប់បានគម្រាមកំហែងដល់វត្តមាននៃអង្គការ និងសមាគមនៅកម្ពុជា ដូច្នេះអាចធានាបានថាអ្នកតាមដានសំខាន់ៗត្រូវបានដកចេញ ជាលទ្ធផលអាចបង្កើនឱកាសបន្តការពុករលួយ។

ម្យ៉ាងវិញទៀត ក្រុមហ៊ុនបស្ចិមប្រទេសដែលចង់បង្កើត ឬវិនិយោគនៅកម្ពុជា ខណៈដែលទីផ្សារភាគហ៊ុនជាតិកម្ពុជាទើបបង្កើតនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ដោយមានគំនិតដែលចង់យកផលចំណេញពីទីផ្សារថ្មីដែលមានលក្ខណៈមានហានិភ័យខ្ពស់-ទិន្នផលខ្ពស់ ដូចកម្ពុជាអាចនឹងគិតបន្ថែមទ្វេដង ប្រសិនបើរូបភាពសេដ្ឋកិច្ចត្រូវបានមើលឃើញថាមានហានិភ័យ និងត្រូវយាយីដោយអំពើពុករលួយគ្រាំគ្រែង និងខ្វះខាតនីតិរដ្ឋ។ ការអនុម័តច្បាប់នឹងបង្ហាញពីជំហានដ៏សំខាន់មួយក្នុងគោលបំណងជាក់លាក់របស់រដ្ឋាភិបាលដើម្បីរារាំងនីតិរដ្ឋ ដោយអនុម័តច្បាប់ដែលអាចបំបិទសំឡេងជំទាស់ និងគាបសង្កត់ប្រជាពលរដ្ឋកម្ពុជា។ តាមការបញ្ជាក់ខាងលើ អំពើពុករលួយនឹងកាន់តែកើនឡើង ជាលទ្ធផលនៃការអនុម័តច្បាប់ ដោយសារតែអង្គការផ្នែកតស៊ូមតិមិនអាចចុះបញ្ជីសាជាថ្មីបាន មានន័យថាក្រុមហ៊ុនដែលសម្រេចរស់នៅបន្តទៀតអាចនឹងត្រូវបង្ខំឲ្យចំណាយប្រាក់សូកប៉ាន់កាន់តែច្រើន ដើម្បីការពារខ្លួនពីសកម្មភាពពុករលួយ។

ការដកខ្លួនរបស់ក្រុមហ៊ុនបស្ចិមប្រទេស ព្រោះច្បាប់ស្រដៀងនឹងច្បាប់ស្តីពីសកម្មភាពពុករលួយនៅបរទេសប្រហែលជាស្ថិតក្នុងការពង្រាង ឬអនុម័តរួចទៅហើយនៅប្រទេសលោកខាងលិចដទៃទៀត[3] ជាទូទៅ អាចកាត់បន្ថយឥទ្ធិពលនៃក្រុមហ៊ុនបស្ចិមប្រទេសនៅកម្ពុជា រួមទាំងឥទ្ធិពលផ្នែកសេដ្ឋកិច្ច និងផ្នែកនយោបាយដែលជាលទ្ធផលនៃការបាត់បង់ឥទ្ធិពលនេះ។

**ការអនុម័តច្បាប់នេះនឹងបណ្តាលឲ្យមានការកើនឡើងនៃអំពើពុករលួយ និងស្របជាមួយគ្នាដែរកាត់បន្ថយឥទ្ធិពលផ្នែកសាជីវកម្ម និងផ្នែកនយោបាយរបស់បស្ចិមប្រទេសដែលចាត់ទុកកម្ពុជាជាទីផ្សារថ្មីដ៏មានតម្លៃ។**

**<u>ប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ និងមជ្ឈដ្ឋានដែល(មិន)អំណោយផល</u>**

ដើម្បីឲ្យជំនួយ និងការអភិវឌ្ឍន៍មានប្រសិទ្ធភាពទាមទារនូវ "មជ្ឈដ្ឋានដ៏អំណោយផល" មួយ។ មជ្ឈដ្ឋានដ៏អំណោយផលមួយគួរផ្សារភ្ជាប់នូវរូបភាពច្បាប់ជាវិជ្ជមាន ដែលច្បាប់ត្រូវបានអនុម័តដើម្បីសម្របសម្រួលដល់ជំនួយ និងការអភិវឌ្ឍន៍ដើម្បីជាផលប្រយោជន៍ដល់ជនក្រីក្រ និងដាច់ស្រយាលបំផុត ហើយច្បាប់ទាំងនេះត្រូវតែអនុវត្តឲ្យបានខ្ជាប់ខ្ជួន។ ចំណុចសំខាន់ គឺអំពើ

[2] សៃម៉ុន ម៉ាកស៍ 'ហានិភ័យនៃអំពើពុករលួយបណ្តាលឲ្យហ្វេតអេកកម្រិតអាជីវកម្មក្នុងស្រុក' ឌឹ ខេមបូឌា ដេលី ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១១

[3] ក្នុងខែមេសា ឆ្នាំ២០១១ ប្រទេសអង់គ្លេសបានអនុម័តច្បាប់ដាក់ទោសចំពោះសកម្មភាពសូកប៉ាន់ចំពោះមន្ត្រីសាធារណៈនៅបរទេស។ មានប្រទេសចំនួន ៣៨ ដែលជាសមាជិកនៃ អនុសញ្ញាប្រឆាំងនឹងអំពើសូកប៉ាន់ នៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ។

ពុករលួយ និងនិទណ្ឌភាពគួរតែត្រូវបានកាត់បន្ថយ ហើយបង្កើនគណនេយ្យភាព និងនីតិរដ្ឋដើម្បីការពារ និងលើកកម្ពស់ ដើម្បី "ការអភិវឌ្ឍដ៏មានប្រសិទ្ធិភាព"។

ចំណុចសំខាន់មួយទៀត គឺម្ចាស់ជំនួយគួរតែចាប់អារម្មណ៍ឲ្យបានជិតដល់ចំពោះស្ថានភាពដែលច្បាប់នេះនឹងត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ន ហើយប្រសិនបើអង្គការមិនអាចចុះបញ្ជី ឬចុះបញ្ជីសាជាថ្មីទេនោះ សេវាកម្មសាធារណៈដ៏ចាំបាច់អាចនឹងត្រូវបានរឹតត្បិត ការអភិវឌ្ឍន៍ថ្នាក់សហគមន៍នឹងនៅទ្រឹង ភាពក្រីក្រ និងអំពើពុករលួយនឹងកាន់តែកើនឡើង។ ម្ចាស់ជំនួយត្រូវទទួលខុសត្រូវក្នុងការវាយតម្លៃពីការប្រើប្រាស់មូលនិធិរបស់ខ្លួន ៖ ប្រសិនបើច្បាប់ត្រូវបានអនុម័ត ថវិកាជំនួយផ្គត់ផ្គង់ដល់អង្គការអភិវឌ្ឍ និងតស៊ូមតិជាច្រើននឹងត្រូវបានបញ្ចប់ ដែលអង្គការទាំងនេះកំពុងតែប្រើប្រាស់ថវិកានេះដើម្បីជាប្រយោជន៍ បន្តជួយដល់អ្នកដែលត្រូវការជំនួយខ្លាំងបំផុត គឺប្រជាពលរដ្ឋកម្ពុជា។

ផលប៉ះពាល់អវិជ្ជមានមួយទៀតសម្រាប់ប្រជាពលរដ្ឋកម្ពុជា គឺការអនុម័តច្បាប់ក្នុងទម្រង់បច្ចុប្បន្ននឹងធ្វើឲ្យមានការកើនឡើងនៃវត្តមានសាជីវកម្មរបស់ប្រទេសដទៃ ដូចជា ប្រទេសចិន។ បច្ចុប្បន្ន កម្ពុជាកំពុងតែទទួលប្រយោជន៍ពីតុល្យភាពអំណាច និងឥទ្ធិពល រវាងលោកខាងកើត និងលោកខាងលិច ដែលតំណាងដោយប្រទេសចិន និងសហរដ្ឋអាមេរិក។ ការប្រែប្រួលស្ថានការណ៍ដោយកាត់បន្ថយឥទ្ធិពលផ្នែកសាជីវកម្ម និងផ្នែកនយោបាយរបស់បស្ចិមប្រទេស ដូចបានរៀបរាប់ខាងដើម គឺនឹងបង្កើនដោយមិនអាចចៀសវាងបាននូវឥទ្ធិពលរបស់ប្រទេសដែលមិនសូវយកចិត្តទុកដាក់ចំពោះស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដូចជា ចិន វៀតណាម ម៉ាលេស៊ី និងកូរ៉េខាងត្បូង។ តុល្យភាពរវាងលោកខាងកើត និងលោកខាងលិចនឹងត្រូវបាត់បង់ សញ្ញានៃភាពស្របច្បាប់ដែលហាក់ដូចជាបានមកពីការការពាររបស់អាមេរិកក៏នឹងបាត់បង់ដែរ។ ការបាត់បង់នូវតុល្យភាពនេះមិនត្រឹមតែបង្កឲ្យមានភាពខូចខាតយ៉ាងធ្ងន់ធ្ងរដល់គោលជំហររដ្ឋាភិបាល ដែលកំពុងតែប្រើប្រាស់អំណាចមួយទប់ទល់នឹងអំណាចមួយទៀត ហើយរក្សានូវឯករាជ្យភាពរបស់រដ្ឋាភិបាលនោះទេ ប៉ុន្តែក៏បានបង្កឲ្យមានភាពខូចខាតដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ។ ប្រសិនបើក្រុមហ៊ុនបស្ចិមប្រទេសត្រូវបានបង្ខំឲ្យចាកចេញពីកម្ពុជា ឬមិនអាចបង្កើត ឬវិនិយោគ កម្ពុជានឹងធ្លាក់ចូលស្វ័យ-ប្រវត្តិទៅក្នុងលំហាឥទ្ធិពល ចិនទាំងស្រុង និងមានអ្វីជាច្រើនទៀតភ្ជាប់មកជាមួយ។

ក្រុមហ៊ុនចិនគឺនៅពីក្រោយការបណ្តេញចេញជាច្រើនទូទាំងកម្ពុជា។ មិនតែប៉ុណ្ណោះ ក្រុម-ហ៊ុនចិនក៏បានបំផ្លាញក្រុមគ្រួសារ និងសហគមន៍កម្ពុជាជាច្រើនផងដែរ ដោយមានបំណងកេងចំណេញពីការឡើងថ្លៃនៃអចលវត្ថុ និងការខ្វះខាតឯកសារកម្មសិទ្ធិ ដោយសារតែការលើកលែងឲ្យសកម្មភាពរំលោភសិទ្ធិមនុស្ស តាមរយៈការព្រងើយកន្តើយរបស់ពួកគេ។ ប្រជាពលរដ្ឋក្រីក្ររស់នៅក្នុងតំបន់ប្រជុំជន និងជនបទត្រូវបានបណ្តេញចេញពីដីរបស់ពួកគាត់ ដោយផ្តល់សំណងដែលមិនសមរម្យដើម្បីចៀសផ្លូវឲ្យការអភិវឌ្ឍដ៏ឃោរឃៅ ក្នុងរូបរាងជាហាងទំនិញ ផ្ទះ និងសណ្ឋាគារ

ទំនើបៗ។ ប្រជាពលរដ្ឋច្រើនជាង ២,៦០០គ្រួសារ តួលេខចុងក្រោយប្រហែលជា ៤,០០០គ្រួសារ ត្រូវបានបណ្តេញចេញរួចទៅហើយពីតំបន់បឹងកក់នៅទីក្រុងភ្នំពេញ ដោយសារតែការអភិវឌ្ឍរួមគ្នារវាងក្រុមហ៊ុនស៊ូកាគូ ដែលគ្រប់គ្រងដោយសមាជិកព្រឹទ្ធសភា លោក ឡៅ ម៉េងឃិន និងក្រុម-ហ៊ុនវិនិយោគ អ៊ីន័រ ម៉ុងហ្គោលី អឺដូស ហុង ជុន ដែលជាក្រុមហ៊ុនចិន។ មួយវិញទៀត កម្ពុជាអាចនឹងធ្លាក់ចូលកាន់តែជ្រៅទៅក្នុងឥទ្ធិពលនយោបាយនៃប្រទេសវៀតណាម ប្រសិនបើគ្មានឥទ្ធិពលដ៏មានស្ថិរភាពពីសហរដ្ឋអាមេរិក អាជីវកម្មបស្ចិមប្រទេស និងសង្គមស៊ីវិលអន្តរជាតិ។

**ប្រសិនបើច្បាប់ត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ន ហើយអង្គការទាំងអស់ត្រូវផ្អាកសកម្មភាព កម្ពុជានឹងក្លាយជា "មជ្ឈដ្ឋានមិនអំណោយផល" ដូច្នេះជំនួយ និងការអភិវឌ្ឍត្រូវបានរារាំង និង ជាលទ្ធផល ប្រជាពលរដ្ឋក្រីក្រ និងដាច់ស្រយាលនឹងបាត់បង់នូវសេវាកម្មដ៏សំខាន់ដែលផ្តល់ឲ្យដោយអង្គការ។ម្យ៉ាងវិញទៀត ការដកខ្លួនចេញរបស់ក្រុមហ៊ុនបស្ចិមប្រទេស សំដៅដល់ការកើនឡើងនៃវត្តមានផ្នែកនយោបាយ និងសាជីវកម្មរបស់ប្រទេសក្នុងតំបន់អាស៊ី មានដូចជា ប្រទេសចិន ដែលនឹងធ្វើឲ្យមានការបាត់បង់ជាច្រើនសម្រាប់ប្រជាពលរដ្ឋកម្ពុជា។**

<u>អនុសាសន៍</u>

ក្នុងគោលគំនិត និងការពិតដែលបានរៀបរាប់ក្នុងគោលការណ៍នយោបាយនេះ ម.ស.ម.ក ផ្តល់អនុសាសន៍មួយចំនួនដល់អ្នកពាក់ព័ន្ធដូចខាងក្រោម ៖

*រដ្ឋាភិបាល*

- គួរតែផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការពិគ្រោះយោបល់ដ៏ពិតប្រាកដ ជាមួយសង្គមស៊ីវិល ដើម្បីបង្កើតពង្រាងច្បាប់លើកទីបី
- គួរតែទទួលស្គាល់អនុសាសន៍ពីសង្គមស៊ីវិល និង ម.ស.ម.ក ផងដែរ
- គួរតែលុបចោលនូវពាក្យ "សមាគម" ទាំងអស់ចេញពីច្បាប់ ដើម្បីឲ្យច្បាប់នេះអនុវត្តបានសម្រាប់តែអង្គការប៉ុណ្ណោះ ដូច្នេះអនុញ្ញាតឲ្យការចូលរួមបែបប្រជាធិបតេយ្យរីកលូតលាស់នៅថ្នាក់មូលដ្ឋាន
- គួរតែធានាថាការអនុម័តច្បាប់នេះស្របនឹងច្បាប់រដ្ឋធម្មនុញ្ញ
- គួរតែធានាថាច្បាប់នេះស្របនឹងកាតព្វកិច្ចការពារ និងលើកកម្ពស់សិទ្ធិនៃសេរីភាពបញ្ចេញមតិ និងការជួបប្រជុំ ដែលបានចែងទាំងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ
- គួរតែបង្កើតនូវ "មជ្ឈដ្ឋានដ៏អំណោយផល" និងរូបភាពផ្នែកច្បាប់ដែលមានការអភិវឌ្ឍគឺជាធាតុផ្សំដ៏សំខាន់ដែល (១) ជំនួយនឹងត្រូវបានផ្តល់ និងការអភិវឌ្ឍន៍នឹងត្រូវបានអនុញ្ញាតឲ្យដំណើរការក្នុងវិធីដ៏មានប្រសិទ្ធភាពមួយ (២) ជនក្រីក្រ និងដាច់ស្រយាលត្រូវបានលើកជា

អាទិភាព និង (៣) រដ្ឋាភិបាល និងតួអង្គសំខាន់ៗដទៃធ្វើការរួមគ្នាជាមួយនឹងសង្គមស៊ីវិល និងម្ចាស់ជំនួយដើម្បីធានាថាដំណើរការនេះបានទទួលជោគជ័យ

*រដ្ឋសភា*

- គួរតែបោះឆ្នោតប្រឆាំងនឹងច្បាប់ ក្នុងដំណាក់កាលអនុម័តដោយរដ្ឋសភា ឬយ៉ាងហោចណាស់គួរតែជំរុញឲ្យបទប្បញ្ញត្តិមួយចំនួនត្រូវបានកែលម្អ

*អាជីវកម្មបស្ចិមប្រទេស*

- គួរតែចាប់អារម្មណ៍ឲ្យបានជិតដល់ចំពោះស្ថានភាពដែលច្បាប់នេះនឹងត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ន និងទទួលស្គាល់ថាច្បាប់នឹងមានផលប៉ះពាល់លើពួកគាត់ ៖ ប្រសិនបើអង្គ-ការតស៊ូមតិត្រូវបានបំបិទមាត់ អំពើពុករលួយនឹងកើនឡើង និងរូបភាពសាជីវកម្មនឹងត្រូវបានមើលឃើញថាមានហានិភ័យខ្ពស់ និងមិនអាចវាយតម្លៃបាន មានន័យថាទីផ្សារថ្មីដ៏មានសក្តានុពលភាពដែលអាចផ្តល់ប្រាក់ចំណេញច្រើន នឹងជាអ្វីដែលមិនអាចឈោងដល់
- គួរតែបញ្ឈប់បង្កើតវត្តមាននៅកម្ពុជា វិនិយោគក្នុងទីផ្សារភាគហ៊ុនកម្ពុជា ឬធ្វើសកម្មភាពអាជីវកម្ម ឬសកម្មភាពសាជីវកម្មនៅកម្ពុជា រហូតទាល់តែអាចទុកចិត្តបានថាច្បាប់នឹងមិនត្រូវបានអនុម័តក្នុងទម្រង់ដែលមានឥទ្ធិពលអវិជ្ជមានមកលើពួកគាត់
- គួរតែប្រឆាំងចំពោះច្បាប់ និងដាក់សម្ពាធមកលើរដ្ឋាភិបាលកុំឲ្យអនុម័តច្បាប់នេះក្នុងទម្រង់បច្ចុប្បន្ន

*ម្ចាស់ជំនួយ និងស្ថានទូត*

- ចាប់អារម្មណ៍ឲ្យបានជិតដល់ចំពោះស្ថានភាពដែលច្បាប់នេះនឹងត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ន ព្រោះប្រសិនបើអង្គការមិនអាចចុះបញ្ជី ឬចុះបញ្ជីសាជាថ្មី សេវាកម្មសាធារណៈដ៏ចាំបាច់អាចនឹងត្រូវរឹតត្បិត ការអភិវឌ្ឍកម្រិតសហគមន៍នឹងនៅទ្រឹង ភាពក្រីក្រ និងអំពើពុករលួយនឹងកាន់តែកើនឡើង រូបភាពសាជីវកម្មនឹងត្រូវបានមើលឃើញថាមានហានិភ័យខ្ពស់ និងមិនអាចវាយតម្លៃបាន និងសំឡេងប្រឆាំងនឹងរដ្ឋាភិបាល និងគោលនយោបាយរដ្ឋាភិបាលចុងក្រោយនឹងត្រូវបានបំបិទ
- គួរតែទទួលខុសត្រូវក្នុងការវាយតម្លៃពីការប្រើប្រាស់មូលនិធិរបស់ខ្លួន ប្រសិនបើច្បាប់ត្រូវបានអនុម័ត ថវិកាជំនួយផ្គត់ផ្គង់ដល់អង្គការអភិវឌ្ឍ និងតស៊ូមតិជាច្រើននឹងត្រូវបានបញ្ឈប់ដែលអង្គការទាំងនេះកំពុងតែប្រើប្រាស់ថវិកានេះដើម្បីជាប្រយោជន៍ បន្តជួយដល់អ្នកដែលត្រូវការជំនួយខ្លាំងបំផុត គឺប្រជាពលរដ្ឋកម្ពុជា
- គួរតែចាប់អារម្មណ៍មើលលំហូរចូលនៃសាជីវកម្មចិន និងឥទ្ធិពលនយោបាយ និងអ្វីផ្សេងទៀតដែលនឹងកើតឡើង ប្រសិនបើច្បាប់ត្រូវបានអនុម័តនៅក្នុងទម្រង់បច្ចុប្បន្ន និង

- គួរតែដាក់សម្ពាធលើរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការអនុម័តច្បាប់ក្នុងទម្រង់បច្ចុប្បន្ន និងដាក់សម្ពាធលើរដ្ឋាភិបាលរបស់ខ្លួន និងថ្នាក់តំបន់ដើម្បីដាក់សម្ពាធដូចគ្នានេះក្នុងកម្រិតមួយខ្ពស់តាមដែលអាចទៅបាន

<u>សេចក្តីសន្និដ្ឋាន</u>

ពង្រាងច្បាប់លើកទីបី នៅតែមានចំណុចខ្វះខាតជាច្រើន ទោះបីជាបានបង្ហាញឲ្យឃើញនូវការកែលម្អមួយចំនួនពីពង្រាងលើកទីពីរក៏ដោយ។ ពង្រាងនេះ បានដាក់បញ្ចូលនូវអនុសាសន៍មួយចំនួនរបស់អង្គការ និងម្ចាស់ជំនួយ ដូចជា សិទ្ធិក្នុងការប្តឹងជំទាស់ ប៉ុន្តែខកខាន ឬមិនបានឆ្លើយតបទាំងស្រុងចំពោះចំណុចដទៃទៀតនៅឡើយ។ ម្យ៉ាងវិញទៀត ភាពមិនស្របគ្នា និងភាពមិនច្បាស់លាស់ជាច្រើនដែលបានកត់សម្គាល់ក្នុងពង្រាងលើកទីមួយ និងលើកទីពីរ នៅតែមិនទាន់បានលើកយកមកពិភាក្សា និងអាចបណ្តាលឲ្យមានការភ័ន្តច្រឡំពេលអនាគត។ ច្បាប់គួរតែផ្តោតលើអង្គការដែលមានម្ចាស់ជំនួយដែលមាននិរន្តភាព ជាជាងអង្គការមហាជន និងអង្គការ តូច និង/ឬនៅថ្នាក់ខេត្ត។ ប្រសិនបើអង្គការទាំងនោះទទួលជំនួយលើសពីកម្រិតទាបបំផុតដែលតម្រូវ នៅក្នុងលក្ខ-ខណ្ឌតម្លាភាព ត្រូវដាក់ឲ្យគណនេយ្យរបស់ពួកគេជាសាធារណៈ ដូច្នេះសេចក្តីភ័យខ្លាចរបស់រដ្ឋា-ភិបាលអំពីការក្លែងបន្លំ ការលាងលុយកខ្វក់ និងភេរវកម្ម នឹងត្រូវបានបញ្ចប់។ ប៉ុន្តែ ប្រសិនបើគោលបំណងរបស់រដ្ឋាភិបាលមានលើសពីនេះ ដែលមានដូចជា ការដាក់គំនាបមកលើតស៊ូមតិថ្នាក់មូល-ដ្ឋាន និងកាត់បន្ថយសេរីភាពនៃការជួបប្រជុំ និងបញ្ចេញមតិសម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់រដ្ឋាភិបាលគួរតែនិយាយដោយបើកចំហពីបញ្ហាទាំងនេះ។

ម.ស.ម.ក បញ្ជាក់សាជាថ្មីពីគោលជំហររបស់ខ្លួនថា ច្បាប់គ្រប់គ្រងអង្គការគួរតែត្រូវបានអនុម័តក្នុងទម្រង់ដែលបង្ហាញនូវជំហានច្បាស់លាស់ និងវិជ្ជមាននៅក្នុងការអភិវឌ្ឍ និងប្រជា-ធិតេយ្យូបនីយកម្ម និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំ ដូចដែលបានចែងក្នុងច្បាប់ជាតិ និងអន្តរជាតិ ក៏ដូចជាសិទ្ធិក្នុងច្បាប់រដ្ឋធម្មនុញ្ញដើម្បី "*ចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ*"។ ម.ស.ម.ក សង្ឃឹមថារដ្ឋាភិបាលនឹងទទួលស្គាល់យ៉ាងជាក់ច្បាស់នូវផលប៉ះពាល់ជាវិជ្ជមានរបស់អង្គការចំពោះសង្គមកម្ពុជា ស្របពេលជាមួយគ្នាដែរក៏អនុញ្ញាតឲ្យនយោបាយបែបប្រជាធិបតេយ្យថ្នាក់មូលដ្ឋានអាចរីកលូតលាស់បាន។

សាររបស់រដ្ឋាភិបាល ហាក់ដូចជាចង់បង្ហាញថាច្បាប់បានឆ្លងផុតដំណាក់កាលដែលសង្គមស៊ីវិលអាចផ្តល់យោបល់ ជះឥទ្ធិពល ឬក៏រារាំងចំពោះការអនុម័តច្បាប់នេះហើយ។ ចំណុចនេះហាក់ដូចជាចំណុចដែលមិនអាចបកក្រោយបានឈានចូលមកដល់ ដូច្នេះប្រសិនបើមានឥទ្ធិពលណាមួយដែលសង្គមស៊ីវិលអាចមានចំពោះរដ្ឋាភិបាល និងការអនុម័តច្បាប់ នេះគឺជាពេលដែល

អ្នកពាក់ព័ន្ធផ្សេងៗចាត់វិធានការក្នុងកម្រិតមួយខ្ពស់តាមដែលអាចទៅបាន រួមនឹងអនុសាសន៍ដែលបានដាក់ជូនក្នុងឯកសារគោលនយោបាយនេះ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក អ៊ូ វីរៈ តាមរយៈ +៨៥៥ (0)១២ ៩០ ៩០ ៥១ ឬអ៊ីម៉ែល ouvirak@cchrcambodia.org ឬ លោក រ៉ូបឺត ហ្វីនច៍ +៨៥៥ (0)៧៨ ៨០ ៩៩ ៦០ ឬអ៊ីម៉ែល robert.finch@cchrcambodia.org

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)
ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា